២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៦

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម **ខៀវ មុត** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានក្រសួងគ្រប់គ្រងបរិស្ថាន ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣** ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

* * *

## II ទីស្តីការគណៈរដ្ឋមន្ត្រី

### ១- អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ២៣ អនក្រ.បក**

**ស្តីពីការកំណត់ពីទំនាក់ទំនង**

**រវាងរាជរដ្ឋាភិបាល និង អគ្គិសនីកម្ពុជា**

* * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ របស់ព្រះករុណាព្រះបាទ **សម្តេចព្រះនរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត អគ្គិសនីកម្ពុជា ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- គណរដ្ឋមន្ត្រីយល់ព្រមផង

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១** : អគ្គិសនីកម្ពុជាសរសេរអក្សរកាត់ អ.ក ដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ ត្រូវដំណើរការក្រោយពីការអនុម័តលើលក្ខន្តិកៈ និង ការចុះបញ្ជីធនធានដូចដែលកំណត់ដោយអនុក្រឹត្យនេះ ។ លក្ខន្តិកៈគឺជាចំណងផ្លូវច្បាប់រវាងរាជរដ្ឋាភិបាល ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គិសនីកម្ពុជា ក្រុមប្រឹក្សាភិបាល ប្រធានអគ្គនាយក និងមន្ត្រី បុគ្គលិក និយោជិតដទៃទៀត នៃអគ្គិសនីកម្ពុជា ។

**មាត្រា ២** : រដ្ឋជាម្ចាស់កម្មសិទ្ធិដំបូងនៃអគ្គិសនីកម្ពុជា ។ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និ ថាមពល និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុហៅថា (មន្ត្រីគ្រប់គ្រ ហ៊ុនរដ្ឋ) ជាតំណាងរួមរបស់រដ្ឋក្នុងការគ្រប់គ្រងអគ្គិសនីកម្ពុជាផ្នែកអាជីវក និងការស្វែងរកកំរៃ ។ ក្នុងន័យនេះមន្ត្រី គ្រប់គ្រងហ៊ុនរដ្ឋជាម្ចាស់ភាគហ៊ុនទាំងអស ដែលចេញដោយអគ្គិសនីកម្ពុជា ។

**មាត្រា ៣** : អនុក្រឹត្យនេះ នឹងត្រូវអនុវត្តចំពោះ អគ្គិសនីកម្ពុជានិងអង្គភាពចំណុះរបស់ខ្ល ទាំងអស់ រហូតដល់ពេលដែលរដ្ឋលែងជាម្ចាស់ហ៊ុនភាគច្រើនក្នុងអគ្គិសនីកម្ពុជា អង្គភាពចំណុះ របស់ខ្លួន ។

**មាត្រា ៤** : រដ្ឋអាចលក់ភាគហ៊ុនរបស់ខ្លួនក្នុង អគ្គិសនីកម្ពុជាឬក្នុងអង្គភាពចំណុះណាមួយស្រប តាមនយោបាយនៃរាជរដ្ឋាភិបាល ។

**មាត្រា ៥** : ដោយអគ្គិសនីកម្ពុជាមានលក្ខណៈជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់ អគ្គិសនីកម្ពុជាទទួលខុសត្រូវចំពោះបំណុលរបស់ខ្លួនត្រឹមកំរិតតំលៃនៃធនធានរបស់ខ្លួនតែប៉ុណ្ណោះ ។ ការទទួលខុសត្រូវរបស់រដ្ឋក្នុងឋានៈជាម្ចាស់ហ៊ុននិងម្ចាស់កម្មសិទ្ធិក្នុងអគ្គិសនីកម្ពុជាឬ ម្ចាស់ហ៊ុនណាមួយទៅ អនាគតក្នុងអគ្គិសនីកម្ពុជាមានកំរិតត្រឹមតែដើមទុនដែលខ្លួនបានយកមកចូលប៉ុណ្ណោះ ។

**មាត្រា ៦** : អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យនេះ ព្រមទាំងច្បាប់ដទៃទៀតជាធរមាន អគ្គិសនីកម្ពុជានឹងប្រកបអាជីវកម្មដោយឯករាជភាព ហើយទទួលខុសត្រូវដោយផ្ទាល់ចំពោះកំរៃ និងការខាតបង់របស់ខ្លួន ។

**មាត្រា ៧** : ចាប់ពីពេលត្រូវបានបង្កើត អគ្គិសនីកម្ពុជាត្រូវទទួលដំណពីរដ្ឋក្នុងឋានៈជាម្ចាស់និងជាអ្នកគ្រប់គ្រងលើវិនិយោគទុនលើវិស័យអគ្គិសនីទាំងអស់របស់រដ្ឋហើយមានភារកិច្ចគ្រប់គ្រង ដូចជា ដីធ្លី អាគារ សំភារៈបរិក្ខារដទៃទៀតដើម្បី ផលិតបញ្ជូន និង ចែកចាយថាមពលអគ្គិសនី ។

អគ្គិសនីកម្ពុជាត្រូវទទួលបន្ត នូវបំណុលព្រមទាំងកាតព្វកិច្ចដែលចុះក្នុងកិច្ចសន្យាដែលមានកន្លងមក ។ បុគ្គលិកជាមន្ត្រីក្តី ជានិយោជិតក្តីដែលរាជ រដ្ឋាភិបាលបានចាត់អោយបំរើការ មកទល់បច្ចុប្បន្ននេះនឹងក្លាយជាបុគ្គលិកផ្ទាល់របស់អគ្គិសនីកម្ពុជាតែម្តង ។ បុគ្គលិកទាំងនេះមិនមានសិទ្ធិទាមទារប្រាក់ឧបត្ថម្ភពិសេសអ្វីពីអគ្គិសនីកម្ពុជាដោយសារការផ្លាស់ប្តូរក្របខ័ណ្ឌវិជ្ជាជីវៈរបស់ខ្លួនឡើយ ។

## ជំពូកទី ២

## គោលដៅ សិទ្ធិ និងការទទួលខុសត្រូវរបស់ អគ្គិសនីកម្ពុជា

**មាត្រា ៨ :** អគ្គិសនីកម្ពុជា មានសិទ្ធិ និងមានការទទួលខុសត្រូវក្នុងការផលិត បញ្ជូននិងចែកចាយ ថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ស្របតាមការទទួលខុសត្រូវនិងកាតព្វកិច្ចនៃសេវាកម្មរបស់ខ្លួន ដែលកំណត់ដោយច្បាប់ លក្ខន្តិកៈ អាជ្ញាប័ណ្ណនិងបទបញ្ញត្តិផ្សេងៗ ទៀត នៃរាជរដ្ឋាភិបាល ។

**មាត្រា ៩ :** អគ្គិសនីកម្ពុជា ត្រូវដំណើរការជាសហគ្រាសអាជីវកម្ម មានឯករាជភាពក្នុងការផលិតបញ្ជូននិងចែកចាយនិងឆ្លើយតបអោយបានសមស្របតាមតម្រូវការទីផ្សារ ព្រមទាំង ទទួលខុសត្រូវលើសេវាកម្មរបស់ខ្លួននិងរកកំរៃបង្កើនធនធាន បង្កើតផលប្រយោជន៍សេដ្ឋកិច្ច និងបង្កើនផលិតភាព ពលកម្ម ។

**មាត្រា ១០ :** អគ្គិសនីកម្ពុជា ត្រូវគោរពលក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណដែលចេញ អោយដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីបំរើសេវាកម្មអគ្គិសនីផ្សេងៗ ។ អគ្គិសនីកម្ពុជាត្រូវអនុវត្តអោយបានសំរេច ទិសដៅដែលបានកំណត់ក្នុងផែនការរបស់ក្រុមហ៊ុន និងរាល់លក្ខខ័ណ្ឌនៃគំរោងកិច្ចសន្យា ប្រតិបត្តិការរបស់ក្រុមហ៊ុនដូចមានចែងក្នុង មាត្រា ៤១ និង ៤២ នៃអនុក្រឹត្យនេះ ។

**មាត្រា ១១ :** អគ្គិសនីកម្ពុជាត្រូវកំរិតសកម្មភាពអាជីវកម្មរបស់ ខ្លួនត្រឹមតែអាជីវកម្មណាស្របទៅនឹងទំហំមុខរបរដែលមានចែងច្បាស់ក្នុងលក្ខន្តិកៈរបស់ខ្លួន និងអនុញ្ញាតដោយអាជ្ញាប័ណ្ណដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអោយ ដើម្បីបំរើសេវាកម្មអគ្គិសនី ។

**មាត្រា ១២ :** អគ្គិសនីកម្ពុជា ត្រូវបានអនុញ្ញាតអោយទទួលរ៉ាប់រងការងារដូចខាងក្រោមនេះ ÷

១-ផលិត បញ្ជូននិងចែកចាយថាមពលអគ្គិសនី ក្នុងគោលបំណងបំពេញតម្រូវការរបស់អ្នកជាវគ្រប់ប្រភេទ ។

២-និហរណកម្មថាមពលអគ្គិសនីទៅប្រទេសជិតខាង និងអហរណកម្មថាមពលអគ្គិសនីពី ប្រទេសទាំងនោះមកវិញ ។

៣-ស្ថាបនានិងដំណើរការបណ្តាញអគ្គិសនីជាតិ សំរាប់បញ្ជូនថាមពល ដើម្បីធានាការផ្គត់ផ្គង់អោយមានប្រសិទ្ធភាព ។

៤–ស្ថាបនានិងដំណើរការបណ្តាញរណប សំរាប់ការចែកចាយថាមពលអគ្គិសនិ និង សំរបសំរួលការតភ្ជាប់ និងដំណើរការរបស់អគ្គិសនីកម្ពុជានិងបណ្តាញចែកចាយផ្សេងទៀត ។

៥–លក់ថាមពលអគ្គិសនី និងសេវាកម្មពាក់ព័ន្ធផ្សេងៗទៀត ។

៦–ទទួលទិញ ផ្ទេរនិងប្តូរថាមពលអគ្គិសនីពីផលិតករដទៃទៀត ។

**មាត្រា ១៣** : អគ្គិសនីកម្ពុជា មានសិទ្ធិចូលរួមក្នុងរាល់សកម្មភាពស្របច្បាប់ក្នុងវិស័យអគ្គិសនីសំរាប់បំពេញគោលដៅពាណិជ្ជកម្មរបស់ខ្លួន ។

**មាត្រា ១៤** : អគ្គិសនីកម្ពុជា អាចបង្កើតក្រុមហ៊ុនរណបដទៃទៀត មានលក្ខណៈជានីតិបុគ្គលដាច់ដោយឡែកពីគ្នា ហើយដែលទទួលខុសត្រូវផ្ទាល់រៀងៗខ្លួនស្របតាមច្បាប់ ។

**មាត្រា ១៥** : អគ្គិសនីកម្ពុជា ត្រូវការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់បុគ្គលិកខ្លួន ហើយយកចិត្តទុកដាក់ក្នុងការបង្កើនផលិតភាព និងការពារសុវត្ថិភាពការងាររបស់បុគ្គលិកទាំងនោះ ។

## ជំពូកទី ៣

## ការចុះដើមទុន និង ធនធាន

**មាត្រា១៦** : ប្រភពដើមទុន អគ្គិសនីកម្ពុជាបានមកពី ÷

១–វិភាគទានគ្មានសំណង ដែលផ្តល់ដោយរាជរដ្ឋាភិបាល ។

២–ទ្រព្យសម្បត្តិផ្សេងៗ និង ដីធ្លីដែលរាជរដ្ឋាភិបាលបានផ្ទេរអោយអគ្គិសនីកម្ពុជាស្របតាមមាត្រា ៧ នៃអនុក្រឹត្យនេះ ។

៣–ប្រាក់ដែលចាត់ទុកជាដើមទុន ចេញមកពីការទូទាត់ជាក់ស្តែង និងស្របច្បាប់គណនេយ្យរបស់អគ្គិសនីកម្ពុជា ។

៤–ជំនួយឥតសំណងនិងជំនួយហិរញ្ញវត្ថុផ្សេងៗទៀតដែលអគ្គិសនីកម្ពុជាទទួលហើយមានការយល់ព្រមពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ ។

៥–ប្រភពទុនផ្សេងៗ ទៀតដែលអគ្គិសនីកម្ពុជា និងទទួលតាមការយល់ព្រមពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ ។

**មាត្រា១** : ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវរៀបចំបញ្ជីការដែលមានកត់ត្រា អំពីធនធាន បំណុល និងកាតព្វកិច្ចចេញពីកិច្ចសន្យាទាំងឡាយ ដែលនឹងត្រូវផ្ទេរអោយ

អគ្គិសនីកម្ពុជា អនុលោមតាមមាត្រា ៧ នៃអនុក្រឹត្យនេះ តាមរយៈលិខិតផ្ទេរកម្មសិទ្ធិក្តី តាមកិច្ចសន្យាជួលក្តី តាមកិច្ចសន្យាប្រវាស់ក្តី រាប់បញ្ចូលទាំងសំភារៈបរិក្ខារ ដីធ្លី សំណង់ដែលរដ្ឋបានវិនិយោគមកហើយសំរាប់ ផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនី ។ ការចុះបញ្ជីនេះរាប់បញ្ចូលការជាន់ស្មានតំលៃធនធានដូចដែលមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ ។

**មាត្រា១៨** : អគ្គិសនីកម្ពុជា ត្រូវរក្សាបញ្ជីការនេះ ដោយយកតួលេខតម្លៃធនធានផ្អែកទៅលើអត្រាថយតម្លៃរបស់វា ។

## ជំពូកទី ៤

## រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន និងការប្រព្រឹត្តិទៅ

**មាត្រា១៩** : ម្ចាស់ភាគហ៊ុនក្នុងអគ្គិសនីកម្ពុជាក្នុងឋានៈជាអ្នកផ្តល់វិភាគទានដល់ទុននៃអគ្គិសនីកម្ពុជាត្រូវ ប្រើប្រាស់សិទ្ធិជាម្ចាស់កម្មសិទ្ធិនៃអគ្គិសនីកម្ពុជាដូចដែលមានចែងក្នុងលក្ខន្តិកៈអគ្គិសនីកម្ពុជា ។ ក្នុងករណីដែលម្ចាស់ហ៊ុនមានចំនួនលើសពីមួយ ម្ចាស់ហ៊ុនម្នាក់ៗមានសំឡេងឆ្នោតក្នុងមហាសន្និបាតនៃក្រុមហ៊ុនតាមសមាមាត្រនៃភាគហ៊ុនរបស់ខ្លួន ។

**មាត្រា២០** : លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវមានការយល់ព្រម ពីរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលហើយត្រូវចុះបញ្ជី និង ប្រថាប់ត្រាស្របច្បាប់ ។

លក្ខន្តិកៈនេះត្រូវបញ្ជាក់ចំណុច ពិសេសរបស់អគ្គិសនីកម្ពុជាដូចតទៅ ÷

១–អាស័យដ្ឋាន ។

២–ទីកន្លែងនៃអាជីវកម្ម ។

៣–ទុនចុះបញ្ជី ។

៤–សិទ្ធិ និង កាតព្វកិច្ចរបស់រដ្ឋក្នុងនាមជាម្ចាស់ហ៊ុន ។

៥–វិធីនិងចំនួនទឹកប្រាក់ដើមទុនដែលរដ្ឋដាក់បញ្ចូលជាហ៊ុន ។

៦–រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន មុខងារ សិទ្ធិអំណាយ និង វិធានការ ព្រមទាំងទំរង់បែបបទ ការតេងតាំង ក្រុមប្រឹក្សាភិបាល និងមន្ត្រីក្រុមហ៊ុនដទៃទៀតនិង

៧–តំណាងអគ្គិសនីកម្ពុជាចំពោះមុខច្បាប់ ។

**មាត្រា២១** : ក្នុងករណីដែលរាជរដ្ឋាភិបាលមានបំណងលក់ភាគហ៊ុនរបស់ខ្លួនក្នុងអគ្គិសនីកម្ពុជា លក្ខន្តិកៈ នៃអគ្គិសនីកម្ពុជា ត្រូវកែប្រែដើម្បីបញ្ចូលចំណុចដូចតទៅ ÷

១–ឈ្មោះរបស់ម្ចាស់ភាគហ៊ុនទាំងឡាយ ។

២–សិទ្ធិ និង កាតព្វកិច្ចរបស់ម្ចាស់ភាគហ៊ុនទាំងនោះ ។

៣–ទម្រង់បែបបទសំរាប់ការចេញ និង ការពិនិត្យបញ្ជាក់ភាគហ៊ុន ។

៤–លក្ខខ័ណ្ឌសំរាប់ការប្រើប្រាស់ភាគហ៊ុនទាំងនោះដោយម្ចាស់ភាគហ៊ុន ។

៥–សិទ្ធិ មុខងារ ទម្រង់បែបបទនៃការពិភាក្សា និងការបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុននៅក្នុងមហាសន្និបាតម្ចាស់ភាគហ៊ុន ដោយរួមបញ្ចូលកិច្ចការដែលទាមទារអោយមានការសំរេច ដោយសម្លេងឆ្នោតជាវិជ្ជមាន ៣/៤ ។

៦–ការចាត់តំណាងរបស់ម្ចាស់ភាគហ៊ុនក្នុងក្រុមប្រឹក្សាភិបាលតាមសមាមាត្រនៃហ៊ុន ព្រមទាំងនីតិវិធីសំរាប់ជ្រើសរើសក្រុមប្រឹក្សាភិបាល ។

**មាត្រា២២** : ក្នុងករណីដែលរដ្ឋជាម្ចាស់ហ៊ុនតែឯង អគ្គិសនីកម្ពុជាមិនត្រូវបើកអោយមានមហាសន្និបាតនៃម្ចាស់ហ៊ុនឡើយ ។ មន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋអាចអនុញ្ញាតអោយក្រុមប្រឹក្សាភិបាលរបស់ អគ្គិសនីកម្ពុជាទទួលខុសត្រូវ និងប្រើសិទ្ធិអំណាចនៃរាជរដ្ឋាភិបាលដែលជាម្ចាស់កម្មសិទ្ធិរបស់អគ្គិសនីកម្ពុជា ។

**មាត្រា២៣** : អគ្គិសនីកម្ពុជា ត្រូវមានក្រុមប្រឹក្សាភិបាលដែលមានចំនួនសមាជិកដូចដែលមានចែងក្នុងលក្ខន្តិកៈ ប៉ុន្តែមិនអាចលើសពី ៧ នាក់ឡើយ ។ ក្រុមមប្រឹក្សាភិបាលត្រូវមានតំណាងរបស់ម្ចាស់ហ៊ុន និងបីនាក់ដែលត្រូវបានជ្រើសរើសក្នុងចំណោមសហគមន៍ពាណិជ្ជកម្ម ។ ក្នុងករណីដែលរដ្ឋជាម្ចាស់ហ៊ុនផ្ទាល់មុខ មន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋជាអ្នកតែងតាំងនិងផ្លាស់ប្តូរសមាជិកទាំងអស់នៃក្រុមប្រឹក្សាភិបាល ។ អាណត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់នៅក្នុងលក្ខន្តិកៈ ប៉ុន្តែមិនអាចលើសពី ៥ ឆ្នាំឡើយ ។ អាណត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗអាចបន្តបានច្រើនដងជាប់ៗ គ្នា ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលមិនអាចត្រូវដកពីមុខតំណែងបានមុនអាណត្តិដោយគ្មានមូលហេតុសមរម្យឡើយ ។

**មាត្រា២៤** : សមាជិកម្នាក់ៗនៃក្រុមប្រឹក្សាភិបាលត្រូវមាន កាតព្វកិច្ចផ្ទាល់ចំពោះអគ្គិសនីកម្ពុជា និងម្ចាស់ហ៊ុន ។ ករណីនេះទាមទារអោយសមាជិកទាំងនោះប្រកបតួនាទីរបស់ខ្លួនដោយស្មោះត្រង់ ហើយបំរើចំពោះតែផលប្រយោជន៍របស់អគ្គិសនីកម្ពុជា និង ម្ចាស់ហ៊ុន ។ សមាជិកក្រុមប្រឹក្សាភិបាល មិនត្រូវទទួលការប៉ះពាល់ជាបុគ្គលភាពឡើយចំពោះសកម្មភាពដែលខ្លួនបានបំពេញ ក្នុងឋានៈជាសមាជិកក្រុមប្រឹក្សាភិបាល

លើកលែងតែសកម្មភាពណាដែលផ្ទុយនឹងកាតព្វកិច្ចរបស់ខ្លួន ។

**មាត្រា២៥** : ក្រុមប្រឹក្សាភិបាលបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមបញ្ញត្តិច្បាប់ ហើយលើស ពីនេះទៅ ទៀត ត្រូវទទួលខុសត្រូវ ÷

១– ពិនិត្យ អនុម័ត និងធ្វើអធិការកិច្ចលើការអនុវត្តន៍ផែនការក្រុមហ៊ុនដោយអនុលោមតាមមាត្រា ៤១ នៃអនុក្រឹត្យនេះ ។

២– ពិនិត្យ និង អនុម័តផែនការវិនិយោគ ។

៣– ពិនិត្យ និងអនុម័តបំណុលព្រមទាំងបែបបទហិរញ្ញវត្ថុផ្សេងៗទៀត ។

៤– ពិនិត្យ អនុម័ត និង ត្រួតពិនិត្យការអនុវត្តន៍កិច្ចសន្យាប្រតិបត្តិការអាជីវកម្មរបស់អគ្គិសនីកម្ពុជាដូចដែលមានចែងក្នុង មាត្រា ៤២ នៃអនុក្រឹត្យនេះ ។

៥– កិច្ចការផ្សេងៗ ទៀតដែលបានប្រគល់អោយក្រុមប្រឹក្សាភិបាលស្របតាមលក្ខន្តិកៈក្រុមហ៊ុន ។

**មាត្រា២៦** : ប្រាក់បំណាច់សំរាប់សមាជិកនៃក្រុមប្រឹក្សាភិបាល នឹងត្រូវកំណត់ដោយមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ ។

**មាត្រា២៧** : អគ្គិសនីកម្ពុជា ត្រូវមានប្រធានអគ្គនាយកមួយរូបដែលទទួលខុសត្រូវចំពោះកិច្ចការប្រចាំថ្ងៃរបស់អគ្គិសនីកម្ពុជាស្របតាមភារកិច្ចដែលបានចែងក្នុងលក្ខន្តិកៈ និងក្នុងបទបញ្ជាផ្ទៃក្នុងដែលក្រុមប្រឹក្សាភិបាលបានអនុម័ត ។ ប្រធានអគ្គនាយកអាចជាសមាជិកក្រុមប្រឹក្សាភិបាលផងដែរ តែមិនអាចជាប្រធាននៃក្រុមប្រឹក្សាភិបាលបានទេ ។

**មាត្រា២៨** : មន្ត្រីរាជការដែលកំពុងបំពេញការងាររបស់ខ្លួនជាប្រចាំ ពុំអាចត្រូវបានតែងតាំងបន្ថែមជាប្រធានអគ្គនាយក ឬ ជាបុគ្គលិកប្រភេទណាក្តី របស់អគ្គិសនីកម្ពុជាបានឡើយ ។

## ជំពូកទី ៥

## សិទ្ធិអំណាចខាងពាណិជ្ជកម្ម

**មាត្រា២៩** : អគ្គិសនីកម្ពុជា ត្រូវបានអនុញ្ញាតអោយធ្វើកម្មសិទ្ធិ កាន់កាប់ ប្រើប្រាស់ ជួញដូរ អចលនទ្រព្យ ចលនទ្រព្យទាំងឡាយស្របតាមច្បាប់ ។ ប៉ុន្តែការលក់ធនធានដែលមានតម្លៃស្មើ ឬលើសពី ៥០០.០០០ ដុល្លារអាមេរិកត្រូវមានការអនុម័តព្រមព្រៀងពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋជាមុនសិន ។

**មាត្រា៣០** : អគ្គិសនីកម្ពុជា មានសិទ្ធិចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងអាជីវកម្មណាមួយក៏ដោយ ដើម្បីផ្គត់ផ្គង់សំភារៈបរិក្ខារ ឬសេវាកម្មទាំងឡាយជាមួយក្រុមហ៊ុនក្នុងឬក្រៅប្រទេស ។ អគ្គិសនីកម្ពុជាអាចចុះកិច្ចសន្យា និង កិច្ចព្រមព្រៀងអាជីវកម្មជាមួយភាគីទី ៣ ណាមួយសំរាប់ការផ្តល់ សេវាកម្មអគ្គិសនីរាប់បញ្ចូលទាំងកិច្ច សន្យាផ្គត់ផ្គង់ថាមពលអគ្គិសនីកិច្ចសន្យាបញ្ជូន និងចែកចាយអគ្គិសនី និងកិច្ចសន្យាសំរាប់សេវាកម្មគ្រប់គ្រង ។

**មាត្រា៣១** : ក្រោយពីការយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល អគ្គិសនីកម្ពុជាអាចចូលរួមប្រកបអាជីវកម្ម ឬ ធ្វើវិនិយោគក្នុងក្រុមហ៊ុនដទៃទៀត ។ ក្នុងករណីនេះ អគ្គិសនីកម្ពុជាទទួលខុសត្រូវតែក្នុងកំរិតប្រាក់ហ៊ុនដែលខ្លួនវិនិយោគទៅក្នុងក្រុមហ៊ុននោះប៉ុណ្ណោះ ។

**មាត្រា៣២** : អគ្គិសនីកម្ពុជាមានសិទ្ធិកំណត់លក្ខខ័ណ្ឌការងារសំរាប់បុគ្គលិករបស់ខ្លួនរាប់បញ្ចូលទាំងទឹកប្រាក់បៀវត្ស ប្រាក់ឈ្នួល ប្រាក់បំណាច់ ប្រាក់រង្វាន់ព្រមទាំងកំណត់បញ្ឈប់ការងារ និង វិន័យ ។

**មាត្រា៣៣** : បុគ្គលិកអគ្គិសនីកម្ពុជា មានសិទ្ធិចេញចូលក្នុងបរិវេណដីធ្លី ឬអាគារណាមួយក៏បានដែលជាការចាំបាច់ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ។ អនុលោមតាមច្បាប់ អគ្គិសនីកម្ពុជាមានសិទ្ធិ÷

១–តម្លើង ឬជួសជុលខ្សែអគ្គិសនី និងសំភារៈផ្សេងទៀតនៅក្រោម ឬ នៅពីលើដី ឬផ្លូវណា មួយ ។

២–ប្រើប្រាស់ ដីធ្លី អាគារ ផ្លូវ ស្ពាន ឬជញ្ជាំងណាមួយសំរាប់ជាទម្រខ្សែអគ្គិសនី ឬ សំភារៈ ផ្សេងទៀត ។

## ជំពូកទី ៦

## ស្វ័យភាព ហិរញ្ញវត្ថុ

**មាត្រា៣៤** : អគ្គិសនីកម្ពុជាមានសិទ្ធិបើកគណនី ក្នុងធនាគារយកប្រាក់ចេញចូលចាត់ចែងមូលនិធិរបស់ខ្លួន ដើម្បីសំរេចគោលដៅរបស់ក្រុមហ៊ុន និងបំពេញការទទួលខុសត្រូវ និង ភារកិច្ចក្នុងសេវាកម្មរបស់ខ្លួន ។

**មាត្រា៣៥** : អគ្គិសនីកម្ពុជាមានសិទ្ធិចេញ មូលប័ត្រ លិខិតសន្យា លិខិតធានាផ្សេងៗ លិខិតបំណុលស្របតាមប្រព័ន្ធច្បាប់របស់ខ្លួន ព្រមទាំងផែនការក្រុមហ៊ុនដែលបាន

ចែងក្នុងមាត្រា ៤១ នៃអនុក្រឹត្យនេះ ។ ប្រាក់ចំណូលដែលបានមកពីសកម្មភាពទាំងនោះត្រូវប្រើប្រាស់អោយចំគោលដៅដែលក្រុមប្រឹក្សាភិបាលបានអនុម័តដូចដែលមានចែងក្នុងផែនការរបស់ក្រុមហ៊ុន ។

**មាត្រា៣៦** : ក្រោយពីមានការអនុញ្ញាតអំពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ អគ្គិសនីកម្ពុជាអាចចេញមូលប័ត្រខ្ចីប្រាក់ដែលអាចយកមកប្តូរជាភាគហ៊ុនក្នុងអគ្គិសនីកម្ពុជាបាន ។

**មាត្រា៣៧** : អគ្គិសនីកម្ពុជាត្រូវរៀបចំប្រព័ន្ធហិរញ្ញវត្ថុ និង គណនេយ្យរបស់ខ្លួនស្របតាមច្បាប់ និង បញ្ញត្តិរបស់រាជរដ្ឋាភិបាល ហើយដែលមានលក្ខណៈជាគណនេយ្យអន្តរជាតិ ។

**មាត្រា៣៨** : អគ្គិសនីកម្ពុជាត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុ និង គណនេយ្យនៅរាល់ដំណាច់ឆ្នាំសារពើពន្ធ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ព្រមទាំងម្ចាស់ហ៊ុនដទៃទៀតពិនិត្យ ។ អគ្គិសនីកម្ពុជាត្រូវមាន អ្នកត្រួតពិនិត្យបញ្ជីម្នាក់ ដែលមានបទពិសោធន៍គ្រប់គ្រាន់ និង ឯករាជ្យសំរាប់ធ្វើការត្រួត ពិនិត្យប្រចាំឆ្នាំលើសៀវភៅបញ្ជីទាំងឡាយរបស់ក្រុមហ៊ុន ។

**មាត្រា៣៩** : អគ្គិសនីកម្ពុជាមានកាតព្វកិច្ច ក្នុងការបង់ពន្ធដារ បង់អាករព្រមទាំងពន្ធប្រចាំឆ្នាំផ្សេងៗ ដូច គ្នានឹងសហគ្រាសឯកជនដទៃទៀតដែរ ទៅតាមច្បាប់ជាធរមាន ។

## ជំពូកទី ៧

## ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

**មាត្រា៤០** : មន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋជាអ្នកកំណត់ទិសដៅនិងបញ្ជាក់គោលការណ៍អគ្គិសនី ស្របតាម នយោបាយអភិវឌ្ឍន៍ជាតិនៃរាជរដ្ឋាភិបាល សំរាប់ដំណើរការអគ្គិសនីកម្ពុជា តាមរយៈបញ្ជា ប្រចាំឆ្នាំជាលាយលក្ខអក្សរចំពោះអ្នកតំណាងរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាភិបាល ។ តែបញ្ជានេះពុំត្រូវផ្ទុយនឹងច្បាប់ អនុក្រឹត្យ អាជ្ញាប័ណ្ណ បទបញ្ញត្តិដទៃទៀត និងលក្ខន្តិកៈរបស់អគ្គិសនីកម្ពុជាឡើយ ។

**មាត្រា៤១** : ក្រុមប្រឹក្សាភិបាលរបស់អគ្គិសនីកម្ពុជា ត្រូវអនុម័តរៀងរាល់ឆ្នាំ នូវផែនការរបស់ក្រុមហ៊ុន ដើម្បីដាក់ជូនមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋជារបាយការណ៍ ។ ផែនការនេះត្រូវចែងអំពីសកម្មភាព ដែលអគ្គិសនីកម្ពុជាត្រូវទទួលរ៉ាប់រងដើម្បីសំរេចទិសដៅនិងភារកិច្ចរបស់ខ្លួន ។

ផែនការក្រុមហ៊ុនមាន ៖

១–ផែនការអភិវឌ្ឍន៍ ប្រចាំថ្ងៃរបស់ក្រុមហ៊ុន និងផែនការវិនិយោគទុនព្រមទាំងសេចក្តីពន្យល់អំពីភាពសមស្របរបស់ផែនការនោះជាមួយកម្មវិធីអភិវឌ្ឍន៍រយៈពេលវែងរបស់អគ្គិសនីកម្ពុជា ។

២–ថវិកាប្រចាំឆ្នាំ ។

៣–តារាងលំអិតកំណត់តម្លៃអគ្គិសនី ដោយផ្អែកលើមូលដ្ឋានតម្លៃដើមទាំងអស់ បូកបញ្ចូល និងប្រាក់ចំណេញសមរម្យ ។

៤–ផែនការកិច្ចព្រមព្រៀងហិរញ្ញវត្ថុដែលក្នុងនោះមានចែងពីបំណុល ការចេញមូលប័ត្រ និងការខ្ចីប្រាក់ចាំបាច់ សំរាប់សកម្មភាពរបស់ក្រុមហ៊ុន ។

៥–ផែនការនៃការគ្រប់គ្រងធនធានទាក់ទងទៅនឹងការថែទាំសំភារៈបរិក្ខារអគ្គិសនី និង

៦–លក្ខណៈវិនិច្ឆ័យ សំរាប់វាយតម្លៃប្រតិបត្តិការអាជីវកម្មរបស់អគ្គិសនីកម្ពុជា ។

**មាត្រា៤២** : អគ្គិសនីកម្ពុជា ត្រូវចុះកិច្ចសន្យាប្រតិបត្តិការអាជីវកម្មជាមួយ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដែលមានរយៈវេលាអនុវត្តចំនួនពីរឆ្នាំហើយដែលនៅក្នុងនោះត្រូវមានចែងលំអិត អំពីការទទួលខុសត្រូវសេវាកម្ម និងបទដ្ឋាននៃកិច្ចប្រតិបត្តិការសេវាកម្មរបស់អគ្គិសនីកម្ពុជា ។ កិច្ចសន្យានេះត្រូវឆ្លុះបញ្ចាំងនយោបាយថាមពលជាតិ និង ផែនការអភិវឌ្ឍន៍ជាតិ ហើយត្រូវមានលក្ខណៈស្របតាមច្បាប់ និងបទដ្ឋានច្បាប់នានាព្រមទាំងស្របតាមលក្ខន្តិកៈ ក្រុមហ៊ុនផងដែរ ។

**មាត្រា៤៣** : ក្នុងករណីគ្មានការជំទាស់ពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ អគ្គិសនីកម្ពុជាត្រូវជួល ក្រុមហ៊ុនឯកទេស ដែលគេទទួលស្គាល់នៅលើឆាកអន្តរជាតិ អោយធ្វើអធិការកិច្ចលើការគ្រប់គ្រងរបស់ខ្លួន ៣ ឆ្នាំម្តងៗ ។ ក្រុមប្រឹក្សាភិបាលត្រូវដាក់របាយការណ៍របស់ក្រុមឯកទេសអន្តរជាតិជូនមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ និងគណៈរដ្ឋមន្ត្រីពិនិត្យ ។

**មាត្រា៤៤** : អគ្គិសនីកម្ពុជាព្រមផ្តល់សេវាកម្មរបស់ខ្លួនក្នុងតំបន់ខាតបង់មួយ លុះត្រាណាតែមានចុះក្នុងកិច្ច សន្យាប្រតិបត្តិការអាជីវកម្មហើយលុះណាតែរាជរដ្ឋាភិបាល ធ្វើហិរញ្ញប្បទាន ។

**មាត្រា៤៥** : ចាប់ពីអនុក្រឹត្យនេះចូលជាធរមាន និងដោយមានការយល់ព្រមពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ អគ្គិសនីកម្ពុជាមានសិទ្ធិជាវសេវាកម្មថាមពលអគ្គិសនី បរិក្ខារអគ្គិសនី

អចលនៈវត្ថុ ឬ ចលនៈវត្ថុផ្សេងៗ ដែលអគ្គិសនីកម្ពុជាយល់ថាជាការចាំបាច់សំរាប់ប្រកបអាជីវកម្មរបស់ខ្លួន ក្នុងករណីដែលមានការសងទូទាត់តម្លៃឧបករណ៍ទាំងនោះត្រឹមត្រូវតាមច្បាប់ ។

**មាត្រា៤៦** : រាជរដ្ឋាភិបាលអាចធានានូវការខ្ចីបុលដែលចុះកិច្ចសន្យាដោយអគ្គិសនីកម្ពុជា ស្របទៅនឹងច្បាប់ជាធរមាន ស្តីអំពីការចុះកិច្ចសន្យាហិរញ្ញវត្ថុរបស់រដ្ឋ និងធានាសងតែចំពោះឥណទានដែលអគ្គិសនីកម្ពុជាបានខ្ចី ព្រមទាំងការប្រាក់ ក្នុងករណីដែលរដ្ឋបានធានាជាមុន ដោយចំពោះមុខ និងដោយលាយលក្ខអក្សរ ។

**មាត្រា៤៧** : អគ្គិសនីកម្ពុជាត្រូវគោរពតាមបទបញ្ញត្តិនៃច្បាប់ទាំងឡាយដែលស្ថិតនៅជាធរមាននាបច្ចុប្បន្ន និងទៅអនាគត លើកលែងតែករណីផ្ទុយណាដែលមានចែងក្នុងអនុក្រឹត្យនេះ ។

**មាត្រា៤៨** : សំរាប់រយៈពេល ៣ ឆ្នាំ ដំបូងគិតពីថ្ងៃកំណើតនៃក្រុមហ៊ុន ហើយបន្ទាប់ពីពេលនោះតទៅទៀត បើសិនជាមានការឯកភាពរវាងមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ ក្រុមហ៊ុនត្រូវមានមន្ត្រីត្រួតពិនិត្យ ហិរញ្ញវត្ថុម្នាក់ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៤៩** : មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ÷

ក– ជូនដំណឹងជាលាយលក្ខអក្សរតាមការកំណត់ និងផ្តល់យោបល់ដល់មន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ ក្រុមប្រឹក្សាភិបាល និងប្រធានអគ្គនាយកអំពីភាពមិនប្រក្រតីផ្សេងៗ ដែលបានកើតឡើង ក្នុងការគ្រប់គ្រងដំណើរការព្រមទាំងគណនេយ្យរបស់ក្រុមហ៊ុន ។

ខ– ដឹកនាំការត្រួតពិនិត្យព្រមទាំងសុំសេចក្តីរាយការណ៍ទាំងឡាយដែលខ្លួនយល់ថាជាការចាំបាច់ដើម្បីតាមពិនិត្យរាល់គណនេយ្យរបស់ក្រុមហ៊ុន សំដៅរ៉ាប់រងអោយគោលដៅផ្នែក ពាណិជ្ជកម្មរបស់ក្រុមហ៊ុនបានសំរេចក្នុងលក្ខណៈស្របច្បាប់ និងស្របតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

គ– បំពេញភារកិច្ចដទៃទៀតដែលច្បាប់ ឬ លក្ខន្តិកៈតំរូវ ឬដែលមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋផ្ទេរអោយ ។

**មាត្រា៥០** : មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានសិទ្ធិចូលរួមនៅក្នុងការប្រជុំក្រុមប្រឹក្សាភិបាល តែពុំមានសិទ្ធិបោះឆ្នោតទេ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មានសិទ្ធិត្រួតពិនិត្យ

គ្រប់ពេលវេលាលើបណ្ណាបញ្ជីគណនេយ្យ សៀវភៅកំណត់ហេតុ លិខិតឆ្លើយឆ្លង វិក្កយប័ត្រ បញ្ជីចំណាយ និងឯកសារដទៃទៀត របស់ក្រុមហ៊ុន ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអាចតវ៉ាទៅមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ និងក្រុមប្រឹក្សាភិបាលរាល់សកម្មភាព ឬអំពើណាមួយដែលខ្លួនយល់ថាផ្ទុយនឹងច្បាប់ឬរំលោភលើលក្ខន្តិកៈរបស់ក្រុមហ៊ុន ។ សំណៅមួយច្បាប់នៃលិខិតតវ៉ានេះត្រូវជូនក្រុមប្រឹក្សាភិបាលក្នុងកំឡុងយ៉ាងយូរ ៣ ថ្ងៃ (ថ្ងៃការងារ) ចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតតវ៉ា ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវរក្សាការសម្ងាត់ចំពោះឯកសារ និងព្រឹត្តិការណ៍ទាំងឡាយណាដែលខ្លួនបានដឹងក្នុងក្របខ័ណ្ឌបេសកម្មរបស់ខ្លួន ហើយក្រៅពីភារកិច្ចដែលបានបញ្ជាក់ក្នុងមាត្រា ៤៩, មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអាចផ្សព្វផ្សាយ ឬ រាយការណ៍នូវសកម្មភាព ឬព្រឹត្តិការណ៍ ទាំងនោះបានតែក្នុងកាលៈទេសៈនិងក្របខ័ណ្ឌដែលច្បាប់អនុញ្ញាត ។

**មាត្រា៥១** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃស្ថាប័នពាក់ព័ន្ធ និង អគ្គិសនីកម្ពុជាមានភារកិច្ចអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះតាមសមត្ថកិច្ចរៀងៗ ខ្លួន ។

**មាត្រា៥២** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥៣** : អនុក្រឹត្យនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *